# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
### ស្តីពីការព្យួរកិច្ចសន្យាការងារ រវាងតំណាងកម្មករនិយោជិត និងតំណាងនិយោជក

កាលពីថ្ងៃទីប្រាំ ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ នៅវេលាម៉ោង ១៤:០០ នាទីរសៀល មានការប្រជុំពិភាក្សាស្តីពីការព្យួរកិច្ចសន្យាការងារ នៅផ្ទះសំណាក់ ឪណាតាអង្គរ ដែលមានទីតាំងនៅ ផ្លូវតាភុល ភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

**សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖**

| | | |
|---|---|---|
| **ក-ភាគីនិយោជក (តំណាងម្ចាស់ផ្ទះសំណាក់)** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| ១- លោកស្រី ឪ វណ្ណរចនា | នាយិកា | 077 566 669 |
| **ខ-ភាគីកម្មករនិយោជិត (តំណាងកម្មករ)** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| ១- លោក ហេង សុធា | អ្នកគ្រប់គ្រង | 077 447 900 |
| ២- លោក ចុន ចិន | ប្រតិភូបុគ្គលិក | 097 942 7722 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរ អោយស្របតាមសេចក្តីណែនាំលេខ ០៤៥/២០ កប/ស.ណន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារ ចំពោះកម្មករនិយោជិត មួយចំនួនក្នុងរយៈពេលចំនួន ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ចំនួន ៤០ (សែសិប)ដុល្លាអាមេរិច ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សម្រាប់ក្រុមហ៊ុនមិនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ទៅដល់បុគ្គលិកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ពីជំងឺ Covid-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូល។

ការពិភាក្សានៃអង្គប្រជុំនេះ ត្រូវបានបញ្ចប់នៅវេលាម៉ោង ១៥:៣០ នាទីរសៀល នាថ្ងៃទីប្រាំ ខែមិថុនា ឆ្នាំពីរពាន់ម្ភៃដដែល ដោយមានការចុះហត្ថលេខាព្រមព្រៀងរបស់តំណាងភាគីទាំងពីរ ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើនេះ បង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

| | |
|---|---|
| **ភាគីតំណាងនិយោជក** | **ភាគីតំណាងកម្មករនិយោជិត** |
| ហត្ថលេខា/ស្នាមមេដៃ | ហត្ថលេខា/ស្នាមមេដៃ |
| ព្រះរាជាណាចក្រកម្ពុជា ឪណាតា អង្គរ ... A ANGKOR KINGDOM OF CAMBODIA | ហេង សុធា    ចុន ចិន |